# ការតស៊ូដោយពលរដ្ឋ៖ ការក្រមើលមើលដំបូង

## ការតស៊ូដោយពលរដ្ឋ

តើការតស៊ូដោយពលរដ្ឋជាអ្វី? ការតស៊ូដោយពលរដ្ឋ ជាវិធីសម្រាប់ប្រពលរដ្ឋសាមញ្ញតស៊ូដើម្បីទាមទារសិទ្ធិ សេរីភាព និងយុត្តិធម៌សម្រាប់ខ្លួនគេដោយមិនប្រើហិង្សា។ ប្រជាពលរដ្ឋដែលចូលរួមក្នុងការតស៊ូនេះ ប្រើប្រាស់យុទ្ធវិធីផ្សេងៗគ្នា ដូចជា កូដកម្ម ពហិកា បាតុកម្មទ្រង់ទ្រាយធំ និងសកម្មភាពផ្សេងៗទៀត ដើម្បីបង្កើតឱ្យមានការផ្លាស់ប្តូរដ៏ទូលំទូលាយទាំងផ្នែក សេដ្ឋកិច្ច សង្គម និងនយោបាយ។ នៅជុំវិញពិភពលោក ការតស៊ូដោយពលរដ្ឋត្រូវបានគេហៅឈ្មោះខុសៗគ្នា ការតស៊ូដោយអហិង្សា សកម្មភាពដោយផ្ទាល់ អំណាចពលរដ្ឋ ការប្រឆាំងផ្នែកនយោបាយ និងការកៀងគរពលរដ្ឋ ប៉ុន្តែមិនថាប្រើឈ្មោះណាមួយនោះទេ កម្លាំងជាមូលដ្ឋានគ្រឹះនៃការតស៊ូដោយពលរដ្ឋ គឺមានសារៈសំខាន់ដូចៗគ្នា។

ចលនាតស៊ូដោយពលរដ្ឋ មានអនុភាពដោយសារតែចលនានេះប្រមូលផ្តុំការចូលរួមជាទ្រង់ទ្រាយធំ ក្នុងសកម្មភាពតបតនឹងការគាបសង្កត់ តាមរយៈការផ្តល់នូវទស្សនៈវិស័យថ្មីមួយ ពីសង្គមមួយដែលមានសេរីភាពជាងមុន មានយុត្តិធម៌ជាងមុន ហើយក៏អាចជាភក្តីភាពនៃបុគ្គលដែលអនុវត្តប្រព័ន្ធចាស់ផងដែរ។ នៅពេលដែលមនុស្សជ្រើសរើសយកការបញ្ឈប់កិច្ចសហការណ៍របស់ពួកគេជាមួយនឹងអ្នកដឹកនាំដែលគ្មានយុត្តិធម៌ ប្រព័ន្ធនោះនឹងក្លាយទៅជាប្រព័ន្ធដែលត្រូវការចំណាយកាន់តែច្រើនក្នុងការគ្រប់គ្រង។ នៅពេលដែលមានចំនួនមនុស្សគ្រប់គ្រាន់ សម្រេចថាមិនគោរពតាម ប្រព័ន្ធនោះនឹងក្លាយទៅជាអនិរន្តភាព ហើយប្រព័ន្ធនោះចាំបាច់ត្រូវតែផ្លាស់ប្តូរ ឬក៏ដួលរំលំ។ ទោះបីជានៅពេលដែលគូបដិបក្ខនៃការតស៊ូដោយពលរដ្ឋ មានអាវុធគ្រប់គ្រាន់ និងមានធនធានគ្រប់គ្រាន់ ពួកគេតែងតែមិនអាចទប់ទល់នឹងការមិនគោរព និងការរំខានដោយពលរដ្ឋទ្រង់ទ្រាយធំ តាមរយៈសកម្មភាពតស៊ូដោយអហិង្សាជាលក្ខណៈយុទ្ធសាស្ត្រដែលរីកសាយភាយ។

> *«ចំណុចសំខាន់នៃការតស៊ូ គឺការទាមទារចំណាប់អារម្មណ៍។ ការតស៊ូនៅក្នុងជ្រុងមួយដែលគ្មានអ្នកយកចិត្តទុកដាក់ គឺគ្មានប្រយោជន៍នោះទេ។ ប្រសិនបើអ្នកតស៊ូ អ្នកចាំបាច់ត្រូវតែទាក់ទាញចំណាប់អារម្មណ៍មកលើការងាររបស់អ្នក ឱ្យច្រើនតាមដែលអាចធ្វើទៅបាន។»* – **ម៉ូសែល ចែក អ្នកដឹកនាំ នៃយុទ្ធនាការពហិការបស់អតិថិជនប្រឆាំងនឹងការរើសអើងពូជសាសន៍នៅអាហ្វ្រិកខាងត្បូង។**

ដោយសារហេតុផលនេះហើយ ចលនាតស៊ូដោយអហិង្សា និងយុទ្ធនាការជាច្រើន បានទទួលជ័យជំនះលើគូបដិបក្ខរាប់មិនអស់។ ក្នុងទស្សវត្សរ៍នីមួយៗ នៃសតវត្សរ៍កន្លងមក ក្នុងទ្វីបទាំង៦ ចលនាល្បីៗ ប្រើប្រាស់យុទ្ធសាស្ត្រអហិង្សា ដើម្បីផ្តួលរំលំរបបគាបសង្កត់ ទទួលបានជោគជ័យលើការកាន់កាប់ផ្នែកយោធា និងនាំមកនូវយុត្តិធម៌ និងសេរីភាពដល់សង្គមរបស់ពួកគេ។ ឧទាហរណ៍ ការតស៊ូដោយពលរដ្ឋមានសារៈសំខាន់ជាខ្លាំងក្នុងការបញ្ចប់នូវការរើសអើងពូជសាសន៍នៅអាហ្វ្រិកខាងត្បូង ចលនាអហិង្សានេះក៏ត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី សិទ្ធិពលរដ្ឋ និងសិទ្ធិការងារនៅសហរដ្ឋអាមេរិក ហើយក៏បានទម្លាក់ជនផ្តាច់ការនៅហ្វីលីពីន ឈីលី ឥណ្ឌូនេស៊ី សែប៊ី និងប្រទេសផ្សេងៗទៀត ចលនាអហិង្សានេះក៏ត្រូវបានប្រើប្រាស់ដើម្បីរារាំងការកាន់កាប់ដោយជនបរទេសនៅដាណឺម៉ាក និងទីម័រខាងកើត ចលនានេះក៏សំខាន់ក្នុងការទាមទារឯករាជ្យភាពរបស់ឥណ្ឌាពីចក្រក្រភពអង់គ្លេសដែរ ចលនានេះបានប្តូរលទ្ធផលបោះឆ្នោតដែលកេងបន្លំនៅអឺរ៉ុបខាងកើត បញ្ចប់ការកាន់កាប់របស់ស៊ីរី នៅលីបង់ និងត្រូវបានប្រើប្រាស់នៅក្នុងប្រទេសដ៏ទៃទៀតដើម្បីទាមទារឲ្យមានការគោរពសិទ្ធិមនុស្ស យុត្តិធម៌ និងការគ្រប់គ្រងដោយខ្លួនឯងតាមបែបប្រជាធិបតេយ្យ។

## គោលគំនិតសំខាន់

**ការតស៊ូដោយពលរដ្ឋ ធៀបនឹង អហិង្សាប្រកបដោយសីលធម៌** ការតស៊ូដោយពលរដ្ឋគឺជាទម្រង់នៃការប្រណាំងប្រជែងផ្នែកនយោបាយ។ អហិង្សាប្រកបដោយសីលធម៌ គឺជាបណ្តុំនៃគោលការណ៍ដែលហាមឃាត់ការប្រើប្រាស់អំពើហិង្សា។ អ្នកចូលរួមនៅក្នុងចលនាតស៊ូដោយពលរដ្ឋដែលប្រកបដោយភាពជោគជ័យ ដូចជា ការតស៊ូដើម្បីឯករាជ្យភាពរបស់ឥណ្ឌា និងចលនាសិទ្ធិពលរដ្ឋរបស់សហរដ្ឋអាមេរិក បានបណ្តុះនូវគំនិតអហិង្សាប្រកបដោយសីលធម៌។ ប៉ុន្តែ មិនមានអ្វីក្នុងការតស៊ូដោយពលរដ្ឋ តម្រូវឱ្យអ្នកអនុវត្តប្រកាន់ខ្ជាប់សកម្មភាពអហិង្សាដើម្បីប្រយោជន៍ផ្ទាល់ខ្លួននោះទេ។ ការពិតទៅ ក្នុងប្រវត្តិសាស្ត្រទាំងមូល ពលរដ្ឋដែលជាអ្នកតស៊ូភាគច្រើនទំនងជាមិនត្រូវបានជំរុញទឹកចិត្តដោយអហិង្សាប្រកបដោយសីលធម៌នោះទេ។ ផ្ទុយទៅវិញ ពួកគេត្រូវបានជំរុញទឹកចិត្តដោយការពិត ដែលថាការតស៊ូដោយពលរដ្ឋគឺជាមធ្យោបាយដែលមានប្រសិទ្ធភាពបំផុតសម្រាប់ពួកគេក្នុងការធ្វើការតស៊ូ។

## ឯកទស្សនៈ ធៀបនឹងពហុទស្សនៈ នៃអំណាច

នៅក្នុងសង្គមជាច្រើន ទស្សនៈដែលរីកសាយភាយពាក់ព័ន្ធនឹងអំណាចច្រើនតែជាឯកទស្សនៈ (រូបភាពទី១) ដែលមានន័យថាមនុស្សសាមញ្ញត្រូវបានមើលឃើញថាពឹងផ្អែកទៅលើសុចន្ទៈ ការសម្រេចចិត្ត និងការគាំទ្រនៃរដ្ឋាភិបាល និងស្ថាប័នដ៏ទៃ។ អំណាចត្រូវបានមើលឃើញថាត្រូវបានកាន់កាប់ និងប្រើប្រាស់ដោយបុគ្គលមួយចំនួន ដែលឈរនៅចំណុចកំពូលនៃការដាក់ចេញបញ្ជា ជាបុគ្គលដែលមាន

ទ្រព្យសម្បត្តិច្រើនបំផុតនិងមានសមត្ថភាពប្រើហិង្សា។ ភាពផ្តាច់ មុខនៃអំណាចត្រូវបានមើលឃើញថាជាអ្វីដែលបន្តមានដោយបុគ្គលយូរអង្វែង បិតថេរ និងមិនអាចផ្លាស់ប្តូរបានដោយងាយស្រួលនោះទេ។ ប៉ុន្តែ ការតស៊ូដោយពលរដ្ឋគឺផ្អែកលើការសន្មតផ្សេងៗ ដូចបានរៀបរាប់ដោយពហុទស្សនៈនៃអំណាច (រូបភាពទី២) ដែលមើលឃើញរដ្ឋាភិបាល និងប្រព័ន្ធដែលកាន់អំណាចផ្សេងទៀត កំពុងតែពឹងផ្អែកយ៉ាងទូលំទូលាយទៅលើការអនុលោម ឬការទទួលយកបានរបស់ប្រជាពលរដ្ឋ។ ក្នុងពហុទស្សនៈ អំណាចត្រូវបានមើលឃើញថាផ្អែកលើការធ្វើឱ្យមានសុពលភាព និងការចូលរួមរបស់ផ្នែកជាច្រើននៅក្នុងសង្គម។ វាងាយស្រួលប្រែប្រួលទ្រង់ទ្រាយ តែងតែពឹងផ្អែកលើកម្លាំងរបស់ខ្លួនក្នុងការបំពេញបន្ថែមប្រភពផ្សេងៗដោយសហការណ៍ពីច្រើនស្ថាប័ន និងមនុស្សផ្សេងៗ។ ដូច្នេះ ចលនាតស៊ូដោយពលរដ្ឋបង្កើតយុទ្ធសាស្ត្ររបស់ពួកគេ ផ្អែកលើទស្សនៈមនុស្សដែលរៀបចំនូវសម្ព័ន្ធភាពដ៏ទូលំទូលាយនៃប្រជាពលរដ្ឋធម្មតា ដើម្បីរារាំងសកម្មភាពរបស់រដ្ឋ ទើបអាចបន្សាបឥទ្ធិពល ឬក៏អាចបង្វែរសកម្មភាពនោះបាន។







**សកម្មភាពនៃការខកខាន និងសកម្មភាពនៃប្រតិបត្តិការ** ពលរដ្ឋអ្នកតស៊ូបានប្រើប្រាស់យុទ្ធវិធីរាប់រយខុសប្លែកពីគ្នាក្នុងប្រវត្តិសាស្ត្រ។ ចំណុចទាំងអស់នេះ អាចឱ្យយើងបែងចែកចេញជាពីរប្រភេទខុសៗគ្នា។ សកម្មភាពនៃការខកខាន ជាយុទ្ធវិធីដែលមនុស្សឈប់ធ្វើអ្វីមួយដែលពួកគេតែងតែត្រូវបានរំពឹងទុកថានឹងធ្វើ ឬតម្រូវឱ្យធ្វើ។ ឧទាហរណ៍សកម្មភាពទាំងនោះមានដូចជា កូដកម្មរបស់កម្មករ ការបដិសេធមិនបង់ពន្ធ និងពហិការរបស់អតិថិជន។ សកម្មភាពនៃប្រតិបត្តិការ ជាយុទ្ធវិធីដែលមនុស្សចាប់ផ្តើមធ្វើអ្វីមួយដែលជាធម្មតាពួកគេមិនធ្វើ ឬក៏ត្រូវបានហាមឃាត់។ ឧទាហរណ៍សកម្មភាពទាំងនោះរួមមាន ការតវ៉ា ការធ្វើបាតុកម្មទ្រង់ទ្រាយធំ ការអង្គុយបាតុកម្ម និងទម្រង់ផ្សេងទៀតនៃការមិនគោរពតាមដោយពលរដ្ឋ។ លំដាប់លំដោយនៃយុទ្ធសាស្ត្រ និងយុទ្ធវិធីទាំងនេះ បង្កើននូវថ្លៃចំណាយសម្រាប់គូបដិបក្ខក្នុងការរក្សាស្ថានភាពដដែល។ ការធ្វើបែបនេះ ក៏អាចជំរុញឱ្យមនុស្សសាមញ្ញចូលរួមក្នុងការតស៊ូ ដោយសារតែប្រភេទនៃយុទ្ធវិធីអាចមានច្រើនផ្សេងៗគ្នា ដូចជាការធ្វើដោយមានហានិភ័យខ្ពស់ និងហានិភ័យទាបដោយសាធារណជន និងឯកជន ការធ្វើផ្តុំគ្នា ឬដោយវិមជ្ឈការ ដែលអាចធ្វើឱ្យមនុស្សមកពីផ្នែកផ្សេងៗនៃសង្គមចូលរួមបាន។

**សាមគ្គីភាព ផែនការ និងវិន័យអហិង្សា** គោលការណ៍សំខាន់បី នៃការតស៊ូដោយពលរដ្ឋអាចធ្វើទៅបានដោយជោគជ័យ គឺសាមគ្គីភាព ផែនការ និងវិន័យអហិង្សា។ សាមគ្គីភាព ត្រូវបានបង្កើតតាមរយៈការកៀងគរផ្នែកផ្សេងៗនៃសង្គម ដែលដំបូងឡើយអាចនឹងមានទុក្ខកង្វល់ផ្សេងៗគ្នា ឱ្យមកផ្តោតជុំវិញបណ្តុំនៃគោលបំណងដែលអាចសម្រេចបាន។ ផែនការ គឺជាលំដាប់លំដោយយុទ្ធសាស្ត្រនៃការធ្វើយុទ្ធនាការ និងយុទ្ធវិធីផ្អែកលើការវិភាគដោយប្រុងប្រយ័ត្ន នៃលក្ខខណ្ឌ និងឱកាសសម្រាប់ធ្វើសកម្មភាព។ ការធ្វើបែបនេះក៏ពាក់ព័ន្ធនឹងការប្រមើលមើលនូវដំណើរដើរថយក្រោយ និងមានផែនការសម្រាប់ប្រើក្នុងគ្រាអាសន្នសម្រាប់ពួកគេ។ វិន័យអហិង្សា ពាក់ព័ន្ធនឹងការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្រក្នុងការប្រើប្រាស់យុទ្ធវិធីដែលអហិង្សា ដោយសារតែហិង្សាអាចកាត់បន្ថយនូវការចូលរួមរបស់ប្រជាពលរដ្ឋធម្មតា ធ្វើឱ្យខូចខាតដល់ភាពស្របច្បាប់នៃចលនា កាត់បន្ថយនូវការគាំទ្រអន្តរជាតិ និងឱកាសនៃការផ្លាស់ប្តូរដោយភក្តីភាព។

**សំណួរនាំ១០**

**១. តើមេដឹកនាំដែលមានអំណាចអាចនឹងត្រូវបានយកឈ្នះ ដោយក្រុមប្រជាពលរដ្ឋសាមញ្ញដែលប្រើប្រាស់ការតស៊ូដោយពលរដ្ឋបាន ដោយរបៀបណា?**

ពុំមានមេដឹកនាំណាដែលមានអំណាចដោយឯកឯងតែម្តងនោះទេ។ មេដឹកនាំមានអំណាច គឺនៅពេលដែលពួកគេមានការគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីមនុស្សម្នារាប់ពាន់ ឬរាប់លាននាក់ក្នុងសង្គម។ ដើម្បីឱ្យមេដឹកនាំអាចរក្សាអំណាចគ្រួតត្រា ទាំង ប៉ូលីស ទាហាន តុលាការ និងការិយាធិបតេយ្យ ត្រូវតែធ្វើការងាររបស់ពួកគេរៀងៗខ្លួន។ មនុស្សនៅក្នុងសង្គម ត្រូវតែទៅធ្វើការឱ្យទៀងទាត់ បង់ពន្ធ និងថ្លៃឈ្នួល និងទិញទំនិញនៅលើទីផ្សារ ដែលជាការគាំទ្រដល់អាជីវកម្ម ឬអាជ្ញាប័ណ្ណដែលចេញដោយរដ្ឋ។ អ្នកដែលធ្វើការនៅក្នុងវិស័យដឹកទំនិញតាមនាវា ឬដឹកជញ្ជូន ក៏ដូចជានៅក្នុងវិស័យទំនាក់ទំនង ឬក៏សេវាផ្តល់ឧបករណ៍ប្រើប្រាស់ ត្រូវតែបន្តដឹកជញ្ជូនទំនិញ និងផ្តល់សេវាទាំងនោះ។ ទាំងអស់នេះគ្រាន់តែជាឧទាហរណ៍ខ្លះៗ នៃក្រុមមួយចំនួនដែលការគាំទ្ររបស់ពួកគេ ចាំបាច់សម្រាប់ឱ្យប្រព័ន្ធមួយដំណើរការទៅមុខបាន។

ដោយយល់ពីចំណុចនេះ អ្នករៀបចំការតស៊ូដោយពលរដ្ឋបានបង្កើតយុទ្ធសាស្ត្រដើម្បីធ្វើឱ្យរង្គោះរង្គើនូវការគាំទ្រទាំងនោះ និងធ្វើឱ្យស្ថានភាពបច្ចុប្បន្នពិបាកនឹងរក្សា។ ការកៀងគរមនុស្សជាច្រើនឱ្យមានមតិផ្ទុយ ឬក៏បាតុកម្មអាចនឹងកាត់បន្ថយនូវភាពស្របច្បាប់របស់មេដឹកនាំ ជាពិសេស ប្រសិនបើការបង្ក្រាបត្រូវបានប្រើតទល់នឹងក្រុមមនុស្សដែលកំពុងតែអនុវត្តសិទ្ធិរបស់ពួកគេ។ ការរំខានដល់ការគ្រួតត្រារបស់រដ្ឋ

ចលនាប្រឆាំងអាចបង្កើននូវថ្លៃចំណាយក្នុងការថែរក្សាប្រព័ន្ធមួយ ដល់ចំណុចមួយដែលអ្នកការពារទាំងនោះអាចនឹងមានការសង្ស័យ អំពីអនាគតរបស់ពួកគេ។ នៅពេលដែលភក្ដីភាពរបស់ពួកគេត្រូវបានធ្វើឱ្យរង្គោះរង្គើ រាល់ការបង្ក្រាបណាក៏ដោយ ក៏អាចកាន់តែពិបាកក្នុងការអនុវត្ត។

## ២. តើការតស៊ូដោយពលរដ្ឋចាប់ផ្ដើមឡើងនៅពេលណា?

យុទ្ធនាការតស៊ូដោយពលរដ្ឋដែលជោគជ័យភាគច្រើន ចាប់ផ្ដើមដោយដំបូងគឺកសាងសមត្ថភាពរបស់មនុស្សសាមញ្ញដើម្បីឱ្យធ្វើសកម្មភាព។ យុទ្ធវិធីក្នុងស្រុក មានហានិភ័យទាប ដើម្បីកៀងគរមនុស្ស និងបង្រួបបង្រួមគ្នាអាចមានសារៈសំខាន់ខ្លាំងណាស់។ ឧទាហរណ៍ មុនពេល(មហាត្មៈ)គន្ទី ចាប់ផ្ដើមយុទ្ធនាការតស៊ូដោយពលរដ្ឋរបស់លោកដំបូងនៅក្នុងឥណ្ឌា លោកបានចំណាយពេលរាប់ខែ និងឆ្នាំដើម្បីសួរសុខទុក្ខ និងនិយាយជាមួយមនុស្សធម្មតា ដើម្បីដឹងពីទុក្ខកង្វល់ ក្ដីសង្ឃឹម និងភាពភ័យខ្លាចរបស់ពួកគេ។ លោកបានដឹងថាតើអ្វីអាចយកឈ្នះភក្ដីភាព និងកិច្ចសហការណ៍របស់ពួកគេ។ លោកក៏បានជំរុញឱ្យប្រជាពលរដ្ឋចូលរួមក្នុង «ការងារកសាង» សេវាកម្មក្នុងសហគមន៍ ដែលកសាងនូវការពឹងផ្អែកលើខ្លួនឯងបាន ក្នុងចំណោមមនុស្សដែលបាត់បង់ទំនុកចិត្តលើរដ្ឋ ប៉ុន្តែពីមុនមានអារម្មណ៍ថាខ្លួនគ្មានអំណាចអ្វីក្នុងការធ្វើសកម្មភាពនោះទេ។

នៅពេលដែលយុទ្ធនាការបានកសាងសមត្ថភាពគ្រប់គ្រាន់ ក្នុងការចូលរួមក្នុងទម្រង់នៃការតស៊ូដោយពលរដ្ឋដោយផ្ទាល់ ពួកគេតែងតែចាប់ផ្ដើមសកម្មភាពដោយផ្ទង់ទៅលើបញ្ហាក្នុងស្រុកដែលជាបញ្ហារួមរបស់សាធារណជនមួយចំនួនធំ។ ឧទាហរណ៍ អ្នករៀបចំនៃ ចលនាសាមគ្គីភាពនៅប៉ូឡូញ ចាប់ផ្ដើមដោយការធ្វើកូដកម្មនៅកន្លែងសង់នាវាមួយកន្លែង។ នៅពេលដែលចលនានេះទទួលបានភាពជោគជ័យលើបញ្ហាមួយ និងបង្កើតបាននូវសហជីពកម្មករឯករាជ្យ ភាពជោគជ័យនោះបានជះឥទ្ធិពលផ្នែកផ្លូវចិត្តយ៉ាងខ្លាំងទៅលើជនជាតិប៉ូឡូញទូទាំងប្រទេស ហើយចលនានោះក៏កាន់តែទទួលបានកម្លាំងកាន់តែខ្លាំង។ ដូចគ្នាដែរ ចលនាតស៊ូសិទ្ធិពលរដ្ឋនៅសហរដ្ឋអាមេរិក បានកើនសន្ទុះគាំទ្របន្ទាប់ពីការអង្គុយធ្វើបាតុកម្ម និងពហិកា បានទទួលជោគជ័យក្នុងការបញ្ឈប់ការរើសអើងពូជសាសន៍ក្នុងហាងទំនិញ និងឡានក្រុង នៅទីក្រុងមួយចំនួន នាប៉ែកខាងត្បូងនៃសហរដ្ឋអាមេរិក។ ជាមួយភាពជោគជ័យទាំងនេះ ចលនាបានបង្ហាញពីអំណាចនៃការតស៊ូដោយពលរដ្ឋ ហើយចលនានេះក៏បានទាក់ទាញនូវការចាប់អារម្មណ៍ និងការតាមដានរបស់ប្រជាជាតិទាំងមូល។

## ៣. តើខ្ញុំរៀបចំបាតុកម្មដោយរបៀបណា?

អ្នករៀបចំផែនការយុទ្ធសាស្ត្ររបស់ចលនាមួយ ត្រូវតែកំណត់គោលបំណង ភាពខ្លាំង ភាពខ្សោយ និងសមត្ថភាពនៃចលនារបស់ខ្លួន និងរបស់គូបដិបក្ខផងដែរ ហើយតើមានអ្វីដែលភាគីទីបី និងកត្តាខាងក្រៅអាចជួយបាន។ នៅពេលដែលចលនាមួយបានកំណត់ច្បាស់ពីគោលបំណងរយៈពេលខ្លី មធ្យម និងរយៈពេលវែង និងបានធ្វើការវិភាគអង្គហេតុលម្អិត និងជាប្រព័ន្ធ ពីស្ថានភាពនៃចលនា ដូច្នេះចលនានេះនឹងស្ថិតក្នុងស្ថានភាពដែលល្អជាងមុន ក្នុងការសម្រេចថាតើយុទ្ធវិធីបែបណាដែលចលនានេះគួរតែប្រើ។ ក្នុងចំណុចនោះ ប្រសិនបើចលនាជ្រើសរើសយកបាតុកម្ម ថាជាយុទ្ធវិធីចម្បង និងចង់រៀនអំពីរបៀបធ្វើឱ្យបាតុកម្មបានជោគជ័យ មានធនធានជាច្រើនអាចរកបាន ដែលរៀបរាប់លម្អិតពីផ្នែកបច្ចេកទេស និងយុទ្ធវិធីក្នុងការធ្វើបាតុកម្មនោះ។

## ៤. ប្រសិនបើមិនធ្វើបាតុកម្ម អញ្ចឹងធ្វើអ្វីវិញ?

មនុស្សជាច្រើនគិតថាបាតុកម្ម ជាសកម្មភាពចម្បងនៃចលនាការតស៊ូដោយពលរដ្ឋ។ ប៉ុន្តែ បាតុកម្មគឺគ្រាន់តែជាទម្រង់មួយក្នុងចំណោមយុទ្ធវិធីផ្សេងៗជាច្រើន ដែលពលរដ្ឋអ្នកតស៊ូអាចប្រើក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ។ មានយុទ្ធវិធីដែលត្រូវបានកំណត់ច្រើនជាងពីររយនៃសកម្មភាពអហិង្សា ដែលអាចជ្រើសរើសប្រើប្រាស់បាន។ ការធ្វើពហិកាផ្សេងៗ (អតិថិជន នយោបាយ និងសង្គម) កូដកម្ម ការធ្វើការយឺតជាងមុន ការបដិសេធបង់ថ្លៃឈ្នួល បង់ពន្ធ បង់ថ្លៃសេវា ដាក់ញត្តិ ការមិនគោរពដោយពលរដ្ឋ ការអង្គុយធ្វើបាតុកម្ម ការរាំងខ្ទប់ និងការបង្កើតស្ថាប័នស្រប ជាឧទាហរណ៍មួយចំនួននៃយុទ្ធវិធីជាច្រើនទៀតសម្រាប់ការតស៊ូដោយពលរដ្ឋ។

ជម្រើស និងលំដាប់លំដោយនៃយុទ្ធវិធីពឹងផ្អែកលើការវាយតម្លៃរបស់ចលនា អំពីស្ថានភាពរបស់ខ្លួន ក៏ដូចជា តើអ្វីជាសមត្ថភាព និងគោលបំណងនៃចលនានោះ។ ប្រសិនបើចលនា មិនសូវជាខ្លាំងទេ គេអាចពិចារណាប្រើប្រាស់យុទ្ធវិធីបែបបំបែកជាក្រុម និងមានហានិភ័យទាប ដូចជា ការធ្វើពហិកា ឬក៏ការបង្ហាញនូវនិមិត្តសញ្ញាដោយអនាមិក ដើម្បីកសាងសមត្ថភាពរបស់ចលនា ធ្វើសារ និង ឬរាំងគូប្រជែង។ នៅក្នុងកម្រិតធំជាងនេះ នៅពេលដែលចលនាមានកម្លាំងខ្លាំងជាងមុន គេក៏អាចផ្តោតបន្ថែមលើការប្រើប្រាស់ទម្រង់នៃសកម្មភាព ដូចជា ការប្រមូលផ្តុំគ្នា ការដើរក្បួន បាតុកម្ម ឬក៏ការមិនគោរពដោយពលរដ្ឋទ្រង់ទ្រាយធំ។

អ្វីដែលសំខាន់ត្រូវចាំថាដោយសារតែបាតុកម្ម តែងតែជាសកម្មភាពដែលត្រូវបានឮជាញឹកញាប់សម្រាប់មនុស្សមួយចំនួន ដែលកំពុងតែចង់រៀបចំការតស៊ូដោយពលរដ្ឋ នោះមិនមែនមានន័យថាបាតុកម្ម គឺជាសកម្មភាពតែមួយ ឬល្អបំផុតនោះទេ។ វាផ្អែកលើស្ថានភាពនិមួយៗ មានយុទ្ធវិធីជាច្រើនផ្សេងទៀតដែលអាចផ្តល់នូវលទ្ធផលល្អប្រសើរជាងនេះ ដោយចំណាយតិចជាង សម្រាប់ធ្វើចលនា។ ការច្នៃប្រឌិត និងការគិតបែបយុទ្ធសាស្រ្ត គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការសម្រេចថាតើត្រូវប្រើប្រាស់យុទ្ធវិធីណាមួយ។

## ៥. ចុះប្រសិនបើ ចលនានោះគ្មានអ្នកដឹកនាំដែលមានប្រជាប្រិយភាព?

មានចលនាជាច្រើនក្នុងប្រវត្តិសាស្រ្ត បានដឹកនាំការតស៊ូដោយពលរដ្ឋយ៉ាងមានប្រសិទ្ធភាព ដោយគ្មានអ្នកដឹកនាំដែលមានប្រជាប្រិយភាព។ ចលនាប្រឆាំងការរើសអើងពូជសាសន៍នៅអាហ្វ្រិកខាងត្បូងទទួលបានជោគជ័យយ៉ាងខ្លាំងខណៈពេលដែលអ្នកដឹកនាំកំពុងតែជាប់ក្នុងពន្ធនាគារ និងត្រូវបានកាត់ផ្តាច់ចេញពីចលនា។ អ្វីដែលសំខាន់ជាងភាពទាក់ទាញផ្ទាល់ខ្លួន ឬក៏សមត្ថភាពក្នុងការនិយាយរបស់អ្នកដឹកនាំនៃចលនាផ្អែកលើពលរដ្ឋ គឺចំណេះដឹងអំពីរបៀបដែលគេត្រូវធ្វើជាតំណាង និងស្តាប់អ្នកចូលរួមចម្រុះនៅក្នុងចលនាមួយ ថ្លឹងថ្លែងដោយប្រុងប្រយ័ត្នអំពីការចំណាយ និងហានិភ័យដែលមានក្នុងជម្រើសនៃសកម្មភាព និងការចែករំលែកការសម្រេចចិត្តជាមួយនឹងអ្នកដឹកនាំមូលដ្ឋាន។

បន្ថែមពីនេះទៀត ការពឹងផ្អែកហួសហេតុលើមេដឹកនាំដែលមានប្រជាប្រិយភាព មានហានិភ័យជាពិសេស។ ពេលខ្លះ អ្នកដឹកនាំទាំងនោះអាចនឹងត្រូវបានជ្រើសតាំងដោយមេដឹកនាំ តាមរយៈសំណើបែងចែកអំណាច ឬក៏ពួកគេអាចនឹងត្រូវបានចាប់ខ្លួន។ ចលនាដែលមានភាពជាតំណាង និងមានភាពរឹងមាំ ត្រូវបានរៀបចំឡើង ក្នុងករណីដែលអ្នកដឹកនាំត្រូវបានបញ្ឈប់ ចលនានោះនឹងនៅតែអាចបន្តទៅមុខដោយអ្នកដឹកនាំថ្មីៗ។

## ៦. ចុះប្រសិនបើខ្ញុំគិតថាការតស៊ូដោយពលរដ្ឋនឹងមិនទទួលបានជោគជ័យទេក្នុងប្រទេសរបស់ខ្ញុំ?

ការតស៊ូដោយពលរដ្ឋមិនមែនតែងតែបានទទួលជោគជ័យនោះទេ។ ប៉ុន្តែ ការតស៊ូនេះអាចទទួលជោគជ័យក្នុងប្រទេសជាច្រើនជុំវិញពិភពលោក ដែល «អ្នកជំនាញ» និងអ្នកដ៏ទៃទៀតមានអារម្មណ៍ថាការតស៊ូនេះនឹងមិនធ្វើឱ្យមានការរីកចម្រើននោះទេ។ ឧត្តមសេនីយ៍ អាហ្គុស្តូ ភីណូឆេត នៃប្រទេសឈីលីត្រូវបានចាត់ទុកថាជាជនផ្តាច់ការដែលឃោរឃៅបំផុតនៅក្នុងពិភពលោក ហើយមនុស្សជាច្រើនមិនគិតថាការតស៊ូដោយពលរដ្ឋ ជាកត្តាសំខាន់ក្នុងការដកគាត់ចេញពីអំណាចនោះទេ ប៉ុន្តែនោះជាអ្វីដែលបាន

កើតឡើង។ មានមនុស្សតិចតួចណាស់ដែលសង្ស័យថា ជនផ្តាច់ការស៊ែប៊ី ស្លូបូដែន មីឡូសូវិក ដែលមានឈ្មោះហៅក្រៅថា «មេពេជ្ឈឃាតនៃតំបន់បាល់កង់» ត្រូវបានបង្ខំឱ្យចុះចេញក្រោមការដាក់សម្ពាតដោយអហិង្សា។ ប៉ុន្តែ នៅពេលដែលលោកមីឡូសូវិក បញ្ជាកងទ័ព និងប៉ូលីសរបស់ខ្លួន ឱ្យបង្ក្រាបមនុស្សរាប់រយពាន់នាក់ដែលធ្វើបាតុកម្ម និងទាមទារឱ្យគាត់ចុះចេញពីដំណែង នៅឆ្នាំ២០០០ កងកម្លាំងសន្តិសុខរបស់លោក បានបដិសេធក្នុងការគោរពបញ្ជា នៅចំពោះមុខការកៀងគរទ្រង់ទ្រាយធំសម្បើមរបស់ប្រជាពលរដ្ឋ។ នៅពេលនោះ លោកមីឡូសូវិក គ្មានជម្រើសអ្វីក្រៅពីការចុះចេញពីតំណែងនោះទេ។

ប្រសិនបើអ្នកនៅតែមិនច្បាស់ ថាតើការតស៊ូដោយពលរដ្ឋអាចប្រើប្រាស់បានក្នុងស្ថានភាពរបស់អ្នក អ្នកអាចសាកពិចារណានូវជម្រើសផ្សេងដែលអាចធ្វើទៅបាន ក្នុងករណីដែលជម្រើសនោះប្រាកដនិយម ៖ កំណែទម្រង់ប្រព័ន្ធនយោបាយពីខាងក្នុង ការចូលរួមក្នុងការបោះឆ្នោត ការដាក់ញត្តិក្នុងប្រព័ន្ធច្បាប់ ការចូលរួមក្នុងការចរចា និងកិច្ចសន្ទនាជាមួយនឹងគូបដិបក្ខ អំពាវនាវឱ្យតួអង្គអន្តរជាតិគាំទ្រ និងប៉ុនប៉ងរៀបចំការបះបោរដោយប្រើអាវុធ គឺជាជម្រើសដែលធ្លាប់ត្រូវបានសាកល្បងប្រើក្នុងផ្នែកជាច្រើននៅជុំវិញពិភពលោក។ ខណៈដែលពុំមានភាពប្រាកដប្រជាណាមួយ បញ្ជាក់ថាការតស៊ូដោយពលរដ្ឋនឹងទទួលបានជោគជ័យ ក៏ពុំមានភាពប្រាកដប្រជាណាមួយដែលបញ្ជាក់ថាជម្រើសផ្សេងទៀតនោះនឹងអាចទទួលបានជោគជ័យនោះដែរ។

ដូច្នេះ ការសម្រេចចិត្តសម្រាប់ក្រុមប្រឆាំង ឬក្រុមមិនយល់ស្រប អាចជ្រើសរើសសកម្មភាពដែលមានឱកាសច្រើនបំផុតក្នុងការទទួលបានលទ្ធផលផ្សេងៗដូចខាងក្រោម ការតវ៉ានឹងភាពស្របច្បាប់របស់អ្នកដែលគាបសង្កត់ ការគេចចេញពី ឬក៏ធ្វើឱ្យការបង្ក្រាបគ្មានប្រសិទ្ធភាព និងការជំរុញឱ្យមានការបែកបាក់ក្នុងចំណោមអ្នកដែលកំពុងការពារប្រព័ន្ធដែលមានស្រាប់។ មានក្រុមប្រឆាំងជាច្រើននៅក្នុងប្រវត្តិសាស្ត្រ ដែលបានពិចារណានូវជម្រើសទាំងនេះ តែបានជ្រើសរើសយកការតស៊ូដោយពលរដ្ឋ ថ្វីបើពេលខ្លះ ការតស៊ូនោះត្រូវបានប្រើប្រាស់អមជាមួយមធ្យោបាយបែបប្រពៃណី ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរផ្នែកនយោបាយក៏ដោយ ដូចជា ការបោះឆ្នោត ការតវ៉ាផ្នែកច្បាប់ ការចរចា និងកំណែទម្រង់ប្រព័ន្ធពីខាងក្នុង។

## ៧. ចុះប្រសិនបើគូបដិបក្ខរបស់ខ្ញុំប្រើហិង្សា ?

អ្នកគួរតែរំពឹងទុកជាមុនថា នៅក្នុងអំឡុងពេលណាមួយនោះ គូបដិបក្ខរបស់អ្នកនឹងប្រើហិង្សា។ ក្នុងប្រវត្តិសាស្ត្រ ករណីនេះតែងតែកើតមានឡើង។ ប៉ុន្តែ ការប្រើប្រាស់ហិង្សារបស់គូបដិបក្ខ មិនមែនមានន័យ

ថាការតស៊ូដោយពលរដ្ឋទទួលបរាជ័យនោះទេ។ ចលនាការតស៊ូដោយពលរដ្ឋ តបតនឹងការបង្ក្រាបដោយហិង្សាក្នុងវិធីសាស្រ្តជាច្រើនដែលអាចកាត់បន្ថយប្រសិទ្ធភាព និង/ឬធ្វើឱ្យមានលទ្ធផលផ្ទុយពីការរំពឹងទុកសម្រាប់ជនគាបសង្កត់។

ចំណុចដំបូង ដើម្បីចៀសវាង ឬក៏បិទការបង្ក្រាបដោយហិង្សា ចលនាការតស៊ូដោយពលរដ្ឋអាចចាប់ផ្តើមដោយប្រើប្រាស់យុទ្ធវិធីដែលពិបាកក្នុងការបង្ក្រាបតាមរយៈការប្រើហិង្សា។ ឧទាហរណ៍ ពហិការបស់អតិថិជន ដែលក្នុងនោះមនុស្សម្នាសម្រេចចិត្តមិនទិញទំនិញជាក់លាក់ណាមួយ គឺពិបាកក្នុងការគាបសង្កត់ ដោយសារតែពួកគេត្រូវបានធ្វើវិមជ្ឈការ ហើយពិបាក ឬក៏មិនអាចសម្រាប់របបមួយដើម្បីបញ្ជាក់ឱ្យដឹងថាអ្នកណាខ្លះចូលរួមក្នុងពហិកានេះ ហើយនរណាមិនបានចូលរួម។ ប្រសិនបើការធ្វើបាតុកម្ម ឬការប្រើប្រាស់យុទ្ធវិធីប្រមូលផ្តុំ និងសាធារណៈត្រូវបានបង្ក្រាប ការតស៊ូដោយមិនពាក់ព័ន្ធនឹងនយោបាយ ឬក៏ការធ្វើវិមជ្ឈការ និងយុទ្ធវិធីដែលគ្មានរូបរាង ដូចជាការបដិសេធមិនបង់ថ្លៃ ឬបង់ពន្ធ ឬក៏សូម្បីតែការធ្វើកូដកម្មជាទូទៅក៏អាចជាជម្រើសដ៏ល្អប្រសើរមួយសម្រាប់ការធ្វើចលនាផងដែរ។

ចំណុចទីពីរ ចលនាការតស៊ូដោយពលរដ្ឋអាចប្រើប្រាស់យុទ្ធវិធីដែលបង្កើតថ្មី ដើម្បីធ្វើឱ្យការបង្ក្រាបរបស់គូបដិបក្ខផ្តល់លទ្ធផលផ្ទុយពីការចង់បានរបស់ពួកគេ។ ការលាតត្រដាងការគាបសង្កត់ទៅកាន់ពិភពលោក និងការផ្សព្វផ្សាយការបង្ក្រាប ដោយប្រើរូបភាព និងសាច់រឿងក្នុងប្រទេស អាចធ្វើឱ្យការបង្ក្រាបកាន់តែមានថ្លៃចំណាយច្រើន ពាក់ព័ន្ធនឹងកេរ្តិ៍ឈ្មោះអន្តរជាតិ និងការវិនិយោគ ជាជាងការគិតមកលើចលនានោះ។ មិនមែនការបង្ក្រាបទាំងអស់សុទ្ធតែបានផលផ្ទុយពីការរំពឹងទុកនោះទេ ប៉ុន្តែនៅពេលដែលចលនាមួយមានភាពស្មុគស្មាញ ពន្យារពេល ឬក៏លាតត្រដាងពីធម្មជាតិដ៏អាក្រក់នៃសកម្មភាពបង្ក្រាបជាក់លាក់ណាមួយ លទ្ធផលអាចជាការបាត់បង់ដ៏ធំធេង នៃការគាំទ្រពីសាធារណជន និងអន្តរជាតិ។

ចំណុចទីបី មានករណីតស៊ូដោយពលរដ្ឋជាច្រើន ដូចជានៅក្នុងហ្វីលីពីន ឆ្នាំ១៩៨៦ ឈីលី ឆ្នាំ១៩៨៨ ស៊ែប៊ី ឆ្នាំ២០០០ និងអ៊ុយក្រែន ឆ្នាំ២០០៤ ដែលសមាជិកនៃកងកម្លាំងសន្តិសុខបានចុះចូលជាមួយក្រុមអ្នកប្រឆាំង ដែលកាត់បន្ថយ ឬក៏លុបបំបាត់យ៉ាងមានប្រសិទ្ធភាពនូវសមត្ថភាពការបង្ក្រាបរបស់របបមួយ។ ការចុះចូលនៃកងកម្លាំងសន្តិសុខទាំងនេះ អាចកើតឡើងទៅបាន ដោយសារកិច្ចខំប្រឹងប្រែងដោយផ្ចិតផ្ចង់យូរអង្វែងរបស់ចលនាតស៊ូ ដែលត្រូវបានបង្កើត ដើម្បីបង្វែរភក្តីភាពនៃកងកម្លាំងសន្តិសុខចេញពីរបបនោះ។

> *«ដូច្នេះហើយទើបការបង្ក្រាប ពុំទទួលបានលទ្ធផលដូចអ្វីដែលរំពឹងទុក។ ដោយសារតែវាប្រៀបដូចជាច្បាប់ទីបី របស់ញូវតុន ស្តីពីសកម្មភាព និងប្រតិកម្ម។ នៅពេលដែលអ្នកបង្កើនកម្រិតនៃការបង្ក្រាប ការតស៊ូក៏នឹងកាន់តែកើនឡើងផងដែរ។»*
> – អ៊ីវ៉ាន ម៉ារ៉ូវិច

## ៨. ចុះប្រសិនបើគូសត្រូវរបស់ខ្ញុំ មិនអាចត្រូវបានបញ្ចុះបញ្ចូល?

មិនមែនជាការចាំបាច់អ្វីដែលត្រូវទៅបញ្ចុះបញ្ចូលជនក្បាលរឹង ដែលទទួលខុសត្រូវក្នុងការបង្ក្រាប ដើម្បីយកឈ្នះនោះទេ។ ប៉ុន្តែ អាចនឹងចាំបាច់ដើម្បីបញ្ចុះបញ្ចូលអ្នកគាំទ្រមួយចំនួនរបស់គូសត្រូវអ្នក។

គួរចាំថា ការតស៊ូដោយពលរដ្ឋអាចមានកម្លាំងដោយសារតែការតស៊ូនេះផ្លាស់ប្តូរជំនឿ និងអាកប្បកិរិយារបស់បុគ្គលរាប់ពាន់ ឬរាប់សិបពាន់នាក់ ដែលសកម្មភាពរបស់ពួកគេគាំទ្រដោយផ្ទាល់ ឬដោយប្រយោលចំពោះការគាបសង្កត់។ នៅពេលដែលប្រភពអំណាចរបស់គូប្រកួតប្រជែងរបស់អ្នកត្រូវបានធ្វើឱ្យចុះអន់ថយ នោះទោះបីជាគេត្រូវបានបញ្ចុះបញ្ចូលឬអត់នោះ ក៏មិនសូវជាមានន័យអ្វីទៀតដែរ។ អំណាចរបស់គេត្រូវបានកាត់បន្ថយដល់កម្រិតមួយដែលគេទទួលស្គាល់ថា គេលែងជាអ្នកត្រួតត្រាលទ្ធផលទៀតហើយ ដូច្នេះ គេនឹងត្រូវបង្ខំឱ្យចរចាដើម្បីការផ្លាស់ប្តូរ ទៅរកសណ្តាប់ធ្នាប់ថ្មីមួយ។

ឧទាហរណ៍ នៅឆ្នាំ១៩៨៥ ការធ្វើពហិកាចំពោះអាជីវកម្មរបស់ជនជាតិស្បែកស នៃចលនាប្រឆាំងនឹងការរើសអើងពូជសាសន៍នៅទីក្រុង ផត អេលីហ្សាបេត នៅអាហ្វ្រិកខាងត្បូង បង្កឱ្យមានការខាតបង់ក្នុងកម្រិតដែលពួកគេចាប់ផ្តើមដាក់សម្ពាធទៅលើរដ្ឋាភិបាលឱ្យផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួន។ អាជីវកម្មទាំងនេះ ប្រហែលជាមិនត្រូវបានបញ្ចុះបញ្ចូលឱ្យយល់ស្រប នឹងគោលបំណងរបស់ចលនានោះទេ ប៉ុន្តែពួកគេទទួលស្គាល់ថា វាអាចនឹងសមហេតុផលប្រសិនបើពួកគេទទួលយកតម្រូវការមួយចំនួនរបស់ចលនា ជាជាងបន្តគាំទ្រដល់ការបង្ក្រាបរបស់រដ្ឋាភិបាល។

> *«តាមពិតទៅ អ្វីដែលនាំឱ្យមានការផ្លាស់ប្តូរនៅអាហ្វ្រិកខាងត្បូង គឺការរៀបចំទ្រង់ទ្រាយធំ... ដែលដាក់សម្ពាធទៅលើរដ្ឋ... ទីបំផុតត្រូវផ្លាស់ប្តូរ... ដើម្បី [នាំឱ្យមាន] ភាពជាប់គាំង និងជាភាពជាប់គាំងដែលរដ្ឋមិនអាចឆ្លើយតបបានតទៅទៀត។»* – ដុកទ័រ ចេណិត ធីរី

## ៩. ការធ្វើបែបនេះគឺចំណាយពេលយូរណាស់។ ចុះប្រសិនបើយើងមិនអាចចាំបាន?

ការតស៊ូដោយពលរដ្ឋ មិនមែនតែងតែចំណាយពេលយូរអង្វែងដើម្បីឲ្យមានឥទ្ធិពលនោះទេ។ ខណៈដែលចលនាសាមគ្គីភាព មិនទទួលបានអំណាចរហូតទាល់តែ ១០ឆ្នាំក្រោយមក បន្ទាប់ពីចលនានេះត្រូវបានរៀបចំឡើង ក៏ចលនានេះធ្វើឱ្យបក្សប្រឆាំងនៅក្នុងហ្វីលីពីន ចំណាយពេលត្រឹមតែពីរបីឆ្នាំប៉ុណ្ណោះក្នុងការរៀបចំដើម្បីដេញជនផ្តាច់ការ ហ្វឺឌីណង់ ម៉ាកូស ចេញពីអំណាច។ អ្វីដែលកំណត់នូវភាពជោគជ័យក្នុងការតស៊ូដោយពលរដ្ឋ មិនមែនជាពេលវេលានោះទេ ផ្ទុយទៅវិញ ថាតើចលនាមួយនោះអាចត្រូវបានបង្រួបបង្រួម និងមានយុទ្ធសាស្ត្រក្នុងសកម្មភាពរបស់ខ្លួនដែរឬអត់។

### ១០. តើយើងអាចយកឈ្នះដោយរបៀបណា?

អ្នកអាចមានឱកាសឈ្នះច្រើនជាង ប្រសិនបើចលនា ឬយុទ្ធនាការរបស់អ្នក ប្រកាន់យកគោលការណ៍ដ៏មានប្រជាប្រិយភាព ដូចជា សាមគ្គីភាព ផែនការដោប្រុងប្រយ័ត្ន និងវិន័យអហិង្សា។

*«ភាពខុសគ្នានៃកិច្ចខំប្រឹងប្រែងដោយអហិង្សា គឺថាពួកគេមិនទទួលស្គាល់នូវភាពចាំបាច់នៃវិន័យ ការបណ្តុះបណ្តាល ការធ្វើយុទ្ធសាស្ត្រ ការធ្វើផែនការ ការជ្រើសរើស និងការធ្វើអ្វីដែលបង្កើតឲ្យមានចលនា។ វាមិនអាចកើតឡើងដោយឯកឯងនោះទេ។ វាត្រូវតែធ្វើឡើងដោយលក្ខណៈជាប្រព័ន្ធ»*

– ចេមស៍ ឡូសាន់

សាមគ្គីភាព គឺចាំបាច់ដោយសារតែចលនាតស៊ូអាចមានអំណាចនៅពេលដែលចលនានេះតំណាងឱ្យឆន្ទៈ និងការប្តេជ្ញាចិត្តរបស់ក្រុមមនុស្សភាគច្រើន។ អ្វីដែលសំខាន់ សូមចងចាំថា ការចូលរួមក្នុងចលនាគឺជាការស្ម័គ្រចិត្ត។ មនុស្សចូលរួម និងប្រថុយគ្រោះថ្នាក់ ដោយសារតែពួកគេជឿជាក់លើចលនា។ ប៉ុន្តែ ប្រសិនបើគ្មានសាមគ្គីភាព មានបុព្វហេតុមិនច្បាស់លាស់ ឬគួរឱ្យសង្ស័យ មនុស្សជាច្រើនអាចនឹងសម្រេចចិត្តមិនចូលរួម។ ជាទូទៅ ចលនាតស៊ូដោយពលរដ្ឋដែលជោគជ័យទៅបាន ត្រូវមានការចូលរួមពី បុរស ស្ត្រី កុមារ មនុស្សវ័យកណ្តាល និងមនុស្សចាស់ មកពីមជ្ឈដ្ឋានសាសនា និងជនជាតិផ្សេងៗគ្នា សិស្សនិស្សិត កម្មករ បញ្ញវន្ត សមាជិកនៃសហគមន៍ធុរកិច្ច និងអ្នកផ្សេងទៀត។

ការធ្វើផែនការ មានសារៈសំខាន់គឺដោយសារតែការតស៊ូដោយពលរដ្ឋ ជាការប្រកួតប្រជែងរវាងអ្នកផ្តើមគំនិត ដូចជា យុទ្ធនាការ ចលនា ឬក្រុមពលរដ្ឋ ជាមួយនិងគូបដិបក្ខ។ ក្នុងការប្រកួតប្រជែងបែបនេះ ការរៀបចំ និងយុទ្ធសាស្ត្រតម្រូវឱ្យមានការបំពាក់បំប៉ន និងដឹកនាំកងកម្លាំងដែលបានប្រមូលតាមរយៈចលនាមួយ។ នៅក្នុងការតស៊ូដោយពលរដ្ឋ អ្នកដឹកនាំធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រ និងយុទ្ធវិធីជាច្រើន ដូចជាការវាយតម្លៃវិធីកសាងធនធាន វិធីដែលល្អបំផុតក្នុងការប្រើប្រាស់ធនធាន និងវិធីដែលកេងប្រវ័ញ្ចលើភាពទន់ខ្សោយរបស់គូបដិបក្ខ និងវិធីការពារប្រឆាំងនឹងវិធានការតបត។ ការសម្រេចចិត្តដ៏ល្អ កម្រនឹងត្រូវបានធ្វើឡើងដោយឯកឯង។ ដើម្បីបង្កើតផែនការឱ្យបានល្អ ចំណេះដឹងពីរប្រភេទគឺចាំបាច់ត្រូវតែមាន។ ទីមួយ អ្នកធ្វើយុទ្ធសាស្ត្រ ចាំបាច់ត្រូវមានចំណេះដឹងលម្អិតពីលក្ខខណ្ឌនយោបាយ សេដ្ឋកិច្ច និងសង្គម ដែលពួកគេប្រឈម ហើយពួកគេចាំបាច់ត្រូវយល់ពីផលប្រយោជន៍ និងបំណងប្រាថ្នារបស់ក្រុមផ្សេងៗនៅក្នុងសង្គម។ ទីពីរ អ្នកធ្វើយុទ្ធសាស្ត្រសម្រាប់ចលនាមួយ ចាំបាច់ត្រូវតែដឹងថាតើការតស៊ូដោយអហិង្សាអាចប្រើប្រាស់បានដោយរបៀបណា អ្វីដែលអាចរៀនបានពីបទពិសោធន៍ផ្ទាល់ខ្លួន អំពីប្រភពដូចជាសៀវភៅ ភាពយន្ត និងអ៊ីនធឺណិត និងតាមរយៈការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដែលមានបទពិសោធន៍ក្នុងការរៀបចំការតស៊ូដោយពលរដ្ឋ និងនយោបាយ។

វិន័យអហិង្សាគឺសំខាន់ ដោយសារតែហិង្សានៃចលនាមួយធ្វើឱ្យបាត់បង់នូវប្រសិទ្ធភាពនៃការតស៊ូ ដែលជាធម្មតាអាចនឹងជំរុញ ឬក៏ហាក់ដូចជាផ្តល់ភាពស្របច្បាប់ចំពោះការបង្ក្រាប។ បន្ថែមពីលើនោះ នៅពេលដែលចលនាតស៊ូដោយប្រើហិង្សា ចលនានោះតែងតែបាត់បង់ការចូលរួមពីប្រជាពលរដ្ឋក្នុងសង្គម ដែលមិនប្រថុយនឹងគ្រោះថ្នាក់ជាក់ស្តែងនៃអំពើហិង្សានោះទេ។ ចុងក្រោយ នៅពេលដែលចលនាមួយប្រើអំពើហិង្សាប្រឆាំងនឹងប៉ូលីស ឬយោធា វានឹងកាន់តែពិបាកក្នុងការបំបែកភក្តីភាពក្នុងចំណោមអ្នកការពារប្រព័ន្ធ ហើយអ្នកគាំទ្រចលនាក្នុងចំណោមអ្នកការពារទាំងនោះនឹងបាត់បង់ផងដែរ។ ចំណុចនេះគឺផ្ទុយពីកម្លាំងដែលការតស៊ូដោយពលរដ្ឋអាចបង្កើតឱ្យមាន ជាបុព្វហេតុនៃចលនាមួយ ដែលចង់ឃើញសង្គមមួយដែលមានសេរីភាព និងប្រសើរជាងមុន ដែលផ្តល់ប្រយោជន៍ដល់មនុស្សគ្រប់គ្នា និងសកម្មភាពរបស់ចលនា អំពាវនាវឱ្យមនុស្សសាមញ្ញមកពីគ្រប់មជ្ឈដ្ឋាន ក្លាយជាមានភាពទាក់ទាញចំពោះអ្នកការពារអ្នកកាន់អំណាចបច្ចុប្បន្ន ក៏ដូចជា ចំពោះអ្នកដែលមានបំណងចង់បញ្ចប់ប្រព័ន្ធនេះដែរ។